# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថារបស់ឯកឧត្តម គូម៉ាម៉ារុ យូជិ

## ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុន

## ប្រចាំព្រះរាជាណាចក្រកម្ពុជា

## ថ្លែងក្នុងពិធីសម្ពោធបើកការដ្ឋាន

## គំរោងពង្រីកប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តកំពង់ចាម និងខេត្តបាត់ដំបង

ថ្ងៃទី 16 ខែមិថុនា 2014

- សូមគោរព **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋមន្រ្តី និងជារដ្ឋមន្រ្តីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- សូមគោរព **ឯកឧត្តម ចំន្ទ សុផល** អភិបាលខេត្តបាត់ដំបង
- សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និងអស់លោកទាំងអស់

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានមកចូលរួមពិធីសម្ពោធបើកការដ្ឋាននៅថ្ងៃនេះ សំរាប់ "គំរោងពង្រីកប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តកំពង់ចាម និងខេត្តបាត់ដំបង" ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋមន្រ្តី និងជារដ្ឋមន្រ្តីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។ ខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធមិដ៏ជ្រាលជ្រៅចំពោះឯកឧត្តមរដ្ឋមន្រ្តី ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និងអស់លោកទាំងអស់ ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ ។

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយដើម្បីធ្វើជាសាក្សីនៃការចាប់ផ្តើមគំរោងផ្គត់ផ្គង់ទឹកស្អាតនេះ ដែលនឹងរួមចំណែកដល់សុខុមាលភាពរបស់ប្រជាជននៅទីរួមខេត្តទាំងពីរ គឺខេត្តកំពង់ចាម និងខេត្តបាត់ដំបង ។

ការទទួលបានទឹកស្អាតដើម្បីប្រើប្រាស់ គឺជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៏សហសវត្សរ៏នានារបស់កម្ពុជា ដែលរួមចំណែកដល់ការកែលំអធ្វើអោយប្រសើរឡើងនូវស្ថានភាពជីវភាពរស់នៅ និងសុខភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ដោយហេតុនោះប្រទេសជប៉ុនបាន និងកំពុងផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួនសំរាប់ការកែលំអប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជាចាប់តាំងពីឆ្នាំ 1990 មក ។

គំរោងធំៗដែលក្នុងនោះមានរួមទាំងការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនៅទីក្រុងភ្នំពេញ និង នៅទីក្រុងសៀមរាប ក៏ដូចជាកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយអាជ្ញាធររដ្ឋាករទឹកនៅក្នុងទីក្រុងទាំងនោះជាដើម ត្រូវបានអនុវត្តដោយរដ្ឋាភិបាលជប៉ុន ។ ទាក់ទងទៅនឹងស្ថានភាពផ្គត់ផ្គង់ទឹកស្អាតនៅតាម បណ្តាទីរួមខេត្តនានា ការទទួលបានទឹកស្អាតដើម្បីប្រើប្រាស់នៅតែមានកំរិតទាបនៅឡើយ ដោយសារភាពចាស់ទ្រុឌទ្រោមនៃរោងចក្រប្រព្រឹត្តកម្មទឹកស្អាត ក៏ដូចជាបំពង់ចែកចាយទឹកដែលចាស់ និងមិនគ្រប់គ្រាន់ ។ បន្ទាប់ពីគំរោងមួយទៀតនៃបណ្តាគំរោងជាច្រើនរបស់យើង គឺ “គំរោងផ្លាស់ប្តូរ និង ពង្រីកប្រពន្ធ័ចែកចាយទឹកស្អាតនៅទីរួមខេត្តពោធិសាត់ ខេត្តបាត់ដំបង និងខេត្តព្រះសីហនុ” ត្រូវបានបញ្ចប់នោះ បណ្តាញបញ្ជូន និងចែកចាយទឹកស្អាតនៅទីរួមខេត្តទាំងនោះនឹងត្រូវបានកែលំអទាំងស្រុង ។

រដ្ឋាភិបាលជប៉ុនបានសំរេចផ្តល់ជំនួយឥតសំណងរបស់ខ្លួនចំនួន 3.355.000.000 យ៉េនប្រាក់ជប៉ុន (បីពាន់បីរយហាសិបប្រាំលានយ៉េនប្រាក់ជប៉ុន) ប្រហែលស្មើនឹង 32.400.000 ដុល្លារ៍អាមេរិក (សាមសិបពីរលានបួនសែនដុល្លារ៍អាមេរិក) សំរាប់គំរោងនេះដើម្បីសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងខេត្តបាត់ដំបង និង ខេត្តកំពង់ចាម ។ នៅក្នុងខេត្តបាត់ដំបង មានប្រជាជនតែ 31 ភាគរយប៉ុណ្ណោះដែលអាចទទួលបានទឹកស្អាតដើម្បីប្រើប្រាស់ រីឯនៅខេត្តកំពង់ចាមវិញ គឺមានតែ 33 ភាគរយប៉ុណ្ណោះ ។ នៅពេលដែលគំរោងនេះត្រូវបានបញ្ចប់នោះ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងខេត្តបាត់ដំបង និងក្នុងខេត្តកំពង់ចាមនឹងត្រូវបានពង្រីកហើយអត្រាសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តទាំងពីរនេះ មានបំណងនឹងបង្កើនអោយដល់ 84 ភាគរយនៅក្នុងឆ្នាំ 2019 ។

ខ្ញុំសង្ឃឹមថាគំរោងនេះ ដែលគ្រោងនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ 2016 ខាងមុខនេះ នឹងត្រូវបានអនុវត្តន៏ដោយរលូន និងដោយជោគជ័យ ហើយដែលនឹងរួមចំណែកដល់ការកែលំអធ្វើអោយប្រសើរឡើងនូវស្ថានភាពជីវភាពរស់នៅរបស់ប្រជាជននៅក្នុងតំបន់ទាំងនេះ ។

ចុងក្រោយនេះ ខ្ញុំសង្ឃឹមដោយស្មោះសរថាជំនួយឧបត្ថម្ភគាំទ្រពីសំណាក់ប្រជាជន និងរដ្ឋាភិបាលជប៉ុននេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវចំណងមិត្តភាពដែលមានជាយូរអង្វែងមកហើយរវាងប្រទេសជប៉ុន និង ព្រះរាជាណាចក្រកម្ពុជា ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក-អ្នក ។